Minnesota Department of Education

# ដំបូន្មានការត្រៀមប្រឡងសម្រាប់មាតាបិតាសិស្ស និងគ្រូ

ដំបូន្មានខាងក្រោមសម្រាប់មាតាបិតាសិស្ស និងលោកគ្រូ អ្នកគ្រូ នឹងអាចជួយឲ្យសិស្សអាចត្រៀមខ្លួនបានរួចរាល់ សម្រាប់ការប្រឡងទូទាំងរដ្ឋ

## ការត្រៀមទូទៅ

- សិស្សានុសិស្សគួររៀនមុខវិជ្ជាដែលពាក់ព័ន្ធជាមួយនឹងបទដ្ឋានការសិក្សារបស់រដ្ឋមីណេសូតា ។ សាលារៀនភាគច្រើនក៏បានបង្កើតឲ្យមានឱកាស ការរៀនសូត្រសមរម្យដល់សិស្សដែលមានការប្រឈមខ្ពស់ទៅនឹងការមិនអាចប្រឡងជាប់ចំពោះវិញ្ញាសារប្រឡងទូទាំងរដ្ឋ ។
- ចែករំលែកភាពរំភើបរីករាយ និងចំណាប់អារម្មណ៍របស់អ្នក ចំពោះមុខវិជ្ជាអំណាន គណិតវិទ្យា និងវិទ្យាសាស្ត្រជាមួយកូនរបស់អ្នក ។
- ផ្តល់ឲ្យសិស្សនូវមុខវិជ្ជាសិក្សានៅផ្ទះ
- លើកទឹកចិត្តសិស្សឲ្យអនុវត្តទម្លាប់សិក្សាល្អ។ សិស្សគួរតែបែងចែកពេលវេលាដាច់ដោយឡែកជារៀងរាល់ថ្ងៃសម្រាប់កិច្ចការសាលា ។
- ត្រូវប្រាកដថាកូនរបស់អ្នកមានឱកាសស្គាល់បានច្បាស់ពីទ្រង់ទ្រាយនៃការប្រឡង ។
    - គំរូវិញ្ញាសារប្រឡងអាចជួយសិស្សឲ្យស្គាល់បានច្បាស់ចំពោះទ្រង់ទ្រាយសំណួរការប្រឡង និងប្រភេទសំណួរដែលមាននៅក្នុងវិញ្ញាសារប្រឡង។
    - ការបង្ហាត់សិស្សសម្រាប់វិញ្ញាសារប្រឡងអនឡាញផ្តល់ជូនព័ត៌មានអំពីការប្រើប្រាស់ឧបករណ៍អនឡាញ និងពណ៌នាអំពីការស្វែងរក និងប្រភេទវិញ្ញាសារផ្សេងៗ។
    - ចូលទៅទំព័រវិញ្ញាសារប្រឡង នៅលើគេហទំព័រ MDE សម្រាប់ព័ត៌មានអំពីការចូលមើលលំហាត់គំរូ និងការបង្ហាត់បង្រៀនសិស្ស។ (ចូលទៅ Districts, Schools and Educators > Statewide Testing > Item Samplers។)
- ត្រូវធានាឲ្យសិស្សគេងលក់ល្អពេលយប់ និងញុំាអាហារពេលព្រឹកដែលសម្បូរអាហារូបត្ថម្ភមុនពេលធ្វើការប្រលង។
- ត្រូវលើកទឹកចិត្តឲ្យកូនរបស់ខ្លួនឆ្លើយគ្រប់សំណួរប្រឡងទាំងអស់។

## មុខវិជ្ជាប្រឡងអំណាន

- ត្រូវអានឲ្យកូនស្តាប់ និងលើកទឹកចិត្តឲ្យគេអានឲ្យអ្នកស្តាប់វិញ ។
- ឲ្យកូនរបស់ខ្លួនរៀនបំពេញចំណោទពាក្យ និងចំណោទពាក្យផ្សេងៗទៀត ។
- ត្រូវលើកទឹកចិត្តកូនឲ្យអានសាច់រឿងផ្សាយក្នុងការសែតប្រចាំថ្ងៃ និងចំណាប់អារម្មណ៍ទូទៅនៃសាច់រឿងផ្សាយក្នុងទស្សនាវដ្តី ។
- ត្រូវពិភាក្សាអំពីហេតុការណ៍បច្ចុប្បន្ន និងរឿងរ៉ាវដែលអ្នកអាននៅក្នុងកាសែត ។

## មុខវិជ្ជាប្រឡងគណិតវិទ្យា

- ត្រូវលើកទឹកចិត្តឲ្យកូនចេះប្រើគណិតវិទ្យាប្រចាំថ្ងៃ ។ ពួកគេអាចអនុវត្តគណិតវិទ្យាបានដោយការបង្កើតគម្រោងថវិកាគ្រឿងទេស ធ្វើការពន្យល់អំពីតារាង និងក្រាហ្វនៅក្នុងអត្ថបទកាសែត និង ទស្សនាវដ្ដី ការចែកចំណែកអាហារ ការប្រើបន្ទាត់វាស់វែងរបស់អ្វីមួយ ការវាស់ស្ទង់គ្រឿងផ្សំ ឬការបន្ថែមតម្លៃមកលើដំណើរទិញឥវ៉ាន់ ។
- លេងហ្គេមដែលពាក់ព័ន្ធនឹងលេខ ឬការគណនា ។
- លើកទឹកចិត្តកូនឲ្យគេចេះភ្ជាប់គណិតវិទ្យាដែលគេបានរៀននៅសាលា ជាមួយនឹងកិច្ចការកំសាន្តរបស់គេ មុខវិជ្ជាផ្សេងទៀត និងជីវិតប្រចាំថ្ងៃរបស់ពួកគេ ។

## ការប្រឡងមុខវិជ្ជាវិទ្យាសាស្ត្រ

- ប្រើអត្ថបទវិទ្យាសាស្ត្រដែលចុះផ្សាយនានា ដើម្បីបង្ហាញថា វិទ្យាសាស្ត្រគឺជាអ្វីដែលមានដំណើរការទៅមុខ និងសកម្ម ។
- ត្រូវឲ្យកូនរបស់ខ្លួនរៀនប្រើបំណិនជជីកសួរ ដោយការចូលរួមក្នុងការប្រកួតប្រជែងវិទ្យាសាស្ត្រ ការតាំងពិពណ៌វិទ្យាសាស្ត្រ និងសកម្មភាពផ្សេងៗទៀត ។
- រុករកវិទ្យាសាស្ត្រនៅខាងក្រៅថ្នាក់រៀន – តំបន់ធម្មជាតិ សួនសត្វ និងសារមន្ទីរវិទ្យាសាស្ត្រ ។

## ការប្រើម៉ាស៊ីនគិតលេខ

សួរគ្រូប្រចាំថ្នាក់កូនអ្នក ដើម្បីបានដឹងអំពីរបៀបដែលគ្រូបង្រៀនក្មេងឲ្យចេះប្រើម៉ាស៊ីនគិតលេខនៅសាលា ។ សិស្សមិនអាចខ្ចីម៉ាស៊ីនគិតលេខគ្នាប្រើបានឡើយ ក្នុងអំឡុងពេលប្រឡងវិញ្ញាសារដ្ឋមីណេសូតា ឬមិនអាចអានក្បួនវិធីប្រើម៉ាស៊ីនគិតលេខបានឡើយ ។ សាលារបស់កូនលោកអ្នកមានព័ត៌មានបន្ថែមអំពីពេលណា ដែលសាលាឲ្យសិស្សប្រើម៉ាស៊ីនគិតលេខដោយវិធីណា និងនៅពេលណាក្នុងអំឡុងពេលប្រឡង ។

---

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់ ៖*

Statewide Testing
mde.testing@state.mn.us

Minnesota Department of Education
1500 Highway 36 West
Roseville, MN 55113-4266
http://education.state.mn.us

*ខែកញ្ញា ឆ្នាំ 2016*